21. ព្រះអង្គអើយ
សូមដឹកនាំការដឹកនាំរបស់សាធារណៈរដ្ឋអាហ្វ្រិកភាគកណ្ដាល
ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាលនៅទីនោះ
ដើម្បីអោយប្រយោជន៍បានផ្ដល់ដល់ប្រជាជនរបស់គេផងដែរ។
(យេរេមា៣០:១៧)

22. បិតាអើយ
យើងសូមអធិស្ឋានសម្រាប់គ្រូគង្វាលនៅប្រទេសកាមេរូនដែលនឹងបានដឹ
កនាំដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់
និងមានសេរីភាពពីការលោភលន់ អំនួត និងការអាក្រក់ៗផ្សេងទៀត។
(អេភេសូរ៥:១៨)

23. យើងខ្ញុំសូមអធិស្ឋានសម្រាប់ក្រុមស្ត្រីក្នុងក្ដីសង្ឃឹមTWRនៅបេនីន។
សូមឱ្យព័ន្ធកិច្ចដែលពួកគេបានធ្វើមានប្រសិទ្ធភាពក្នុងការផ្ដល់ឱ្យអ្នកស្ដា
ប់មានក្ដីសង្ឃឹមថ្មី បានពីការដែលបានស្គាល់ព្រះគ្រីស្ទ។ (កិច្ចការ៦:៧)

24.
មានស្ត្រីវ័យក្មេងជាច្រើននៅភាគខាងត្បូងនៃប្រទេសនីហ្សេរីយ៉ាដែលបាន
ពាក់ព័ន្ធនឹងគ្រឿងស្រវឹង និងពេស្យាចារ។ ព្រះវរបិតាអើយ
សូមបង្ហាញប្រាប់ពួកគេថាទ្រង់គឺជាប្រភពនៃការស្កប់ចិត្តតែមួយគត់។
(២កូរិនថូស៤:៤)

25. ព្រះវរបិតាអើយ
សុំផ្ដល់នូវសុខភាពដ៏ប្រពៃដល់ក្រុមការងារទាំងអស់នៅប្រទេសម៉ាលី
ដែលជួយបង្កើត ផលិត
និងចាក់ផ្សាយកម្មវិធីស្ត្រីក្នុងក្ដីសង្ឃឹមនៅទីនោះ។
សូមទ្រង់ប្រទាននូវការធ្វើដំណើរដែលប្រកបដោយសុខសុវត្ថិភាពដល់ក្រុ
មការងាររបស់យើង និង អ្នកសម្របសម្រួលនៅទីនោះផងដែរ។
(ទំនុកដំកើង៥:១១)

26. បិតាអើយ សូមប្រទានកម្លាំងយុវនារីនៅ Côte d'Ivoire
និងពង្រឹងក្ដីជំនឿ
ការប្ដេជ្ញាចិត្តក្នុងការរស់នៅនិងការធ្វើការសម្រាប់អាណាចក្ររបស់ទ្រង់។
យើងក៏អរព្រះគុណទ្រង់ដែលក្រុមការងាររបស់យើងបានផ្ដល់ការអប់រំ
ដល់យុវជនអំពីជំងឺកាមរោគ ការមានផ្ទៃពោះ និងការញៀនថ្នាំផងដែរ។
(សុភាសិត ៣:៥-៨)

27. ព្រះវរបិតាអើយ កូនទូលសូមសុំអោយក្រុមជំនុំនៅហ្គាបុង
បានចូលទៅចំពោះទ្រង់ដោយមានការប្រែចិត្តចេញពីអំពើបាបរបស់ប្រជា
ជាតិរបស់ពួកគេ ក៏ដូចជាពួកគេខ្លួនឯងផងដែរ។ (ដានីយ៉ែល៩:៣-២០)

28. ព្រះអម្ចាស់អើយ
សូមដឹកនាំដួងចិត្តរបស់មេដឹកនាំនៅបេនីនអោយពេញដោយក្ដីមេត្តា
ដើម្បីអោយគេបានជួយដល់ស្ត្រីក្រីក្រ និងខ្វះខាតនៅទីនោះ
រួមទាំងផ្ដល់សិទ្ធិក្នុងការទទួលបានមរតកផងដែរ។ (សុភាសិត២១:១)

29. ព្រះវរបិតាអើយ សូមការពារ
និងពង្រឹងក្ដីជំនឿអ្នកជឿនៅភាគខាងជើង នៃនីហ្សេរីយ៉ា
នៅពេលពួកគេជួបជុំគ្នាដើម្បីអធិស្ឋាន
និងចែកចាយដំណឹងល្អទៅអ្នកដទៃ។ (ទំនុកដំកើង ២៣:៤)

30. ព្រះអម្ចាស់អើយ យើងខ្ញុំសូមលើកតម្កើងព្រះនាមព្រះអង្គឡើង
ចំពោះភាពស្មោះត្រង់របស់ទ្រង់ដែលបានធ្វើការតាមរយៈក្រុមការងាររប
ស់យើង អោយបានប្រមូលផ្ដុំស្ត្រីនៅប្រទេសលីបេរីយ៉ាសម្រាប់ការ
អធិស្ឋាន និងការប្រកបជារៀងរាល់ខែ
ទោះបីជាពេលខ្លះពួកគេប្រឈមនឹងការលំបាកក៏ដោយ។
(១ថែស្សាឡូនិច៥:២៤)

31. បិតាអើយ
យើងពិតជាអរព្រះគុណព្រះអង្គសម្រាប់ការបើកផ្លូវនៃការប្រកាសអំពីដំ
ណឹងល្អរបស់ទ្រង់នៅប្រទេសម៉ាលី និងប្រទេសជុំវិញដូចជា –Guinea
Burkina Faso និង Côte d'Ivoire ផងដែរ។ (ម៉ាថាយ២៨:១៩-២០)

후원안내

국민은행 851-01-0003-724 북방선교방송

최초 입금 후 사무실로 연락 주시기 바랍니다

# Women of Hope
## Prayer Calendar

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង
100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 65,000នាក់



2022. 12.

## ការអធិស្ឋានសម្រាប់ស្ត្រីនៅអាហ្វ្រិកខាងលិច និងកណ្ដាល

កុមារនៅអាហ្រ្វិកតែងតែមិនមានឱកាសទទួលបានការអប់រំ
ដោយសារតែពួកគេបានចូលរួមសកម្មភាពជួយដល់សេដ្ឋកិច្ចគ្រួសាររប
ស់ពួកគេ។ ហើយការនេះត្រឡប់ទៅជាការនាំទៅរក
រង្វង់នៃភាពសាហាវនៃកាតធ្លាក់ចុះទៅរកភាពក្រីក្រម្ដងទៀត
ដែលឈានទៅរកការទទួលបាននូវការអប់រំទាប។
នៅក្នុងប្រទេសដែលមានសង្គ្រាមស៊ីវិល
នៅតែមានកុមារស្លាប់ដោយសារ កង្វះអាហារូបត្ថម្ភ។
សូមអអធិស្ឋានទាំងអស់គ្នាថា
ព្រះនឹងមានសេចក្ដីមេត្តាករុណាដល់ពួកគេផង។


**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 phkorea@twrk.or.kr

**អធិស្ឋានសំរាប់……………**

1. ព្រះអម្ចាស់អើយ
សូមការពារស្ត្រីគ្រីស្ទាននៅអាហ្វ្រិកខាងលិចដែលបានរៀបការជាមួយបុរសដែលមិនមែនជាគ្រីស្ទានហើយត្រូវបង្ខំឱ្យថ្វាយបង្គំព្រះរបស់ស្វាមីពួកគេ។ សូមអោយបុរសទាំងនេះបែរមករកទ្រង់
ហើយបានទទួលការសង្គ្រោះផងដែរ។ (១កូរិនថូស៧:១៣-១៤)

2. បិតាអើយ សូមពង្រឹងក្រុមជំនុំនៅសាធារណរដ្ឋអាហ្វ្រិកភាគកណ្ដាលអោយពួកគេប្រកាន់ជាប់ជាមួយនឹងទ្រង់ដើម្បីទទួលបានប្រាជ្ញា កម្លាំង និងការការពារមកពីទ្រង់ដល់ពួកគេក្នុងការដែលគេឆ្លងកាត់គ្រាលំបាកនានាផងដែរ។ (ទំនុកតម្កើង៧:១)

3. ព្រះអម្ចាស់អើយ
ក្រុមរបស់យើងនៅក្នុងប្រទេសនីហ្សេរីយ៉ាកំពុងផ្តល់ការបណ្តុះបណ្តាលសម្រាប់ស្ត្រីមេផ្ទះដើម្បីបង្កើតស្នាដៃដែលនាំឱ្យពួកគេមានប្រាក់ចំណូល។សូមនាំដួងចិត្តនៃក្រុមជំនុំក្នុងតំបន់ដើម្បីគាំទ្រគម្រោងទាំងនេះ។ (អេភេសូរ៣:២០)

4. ព្រះបិតាអើយ
យើងអធិស្ឋានសម្រាប់គ្រូគង្វាលដែលធ្វើការនៅប្រទេសម៉ាលី។ សូមឱ្យស្ត្រីក្នុងក្តីសង្ឃឹម បើកដួងចិត្តការផ្សាយដំណឹងល្អ និងដួងចិត្តរបស់ពួកគេកសាងក្តីជំនឿរបស់ពួកគេផងដែរ។ (កិច្ចការ១៤:២៧)

5. ព្រះជាម្ចាស់ ពួកយើងអធិស្ឋានសុំនូវសន្តិភាព និងស្ថិរភាពនៅ Côte d'Ivoire ដើម្បីមានឱកាសក្នុងការផ្សព្វផ្សាយដំណឹងល្អដំណើរការយ៉ាងល្អ ហើយក៏ដើម្បីអោយប្រជាជាតិនេះមានការរីកចម្រើនផងដែរ។ (លេវីវិន័យ២៦:៦)

6. ឱព្រះជាអម្ចាស់អើយ
ទូលបង្គំសូមអធិស្ឋានទូលអង្វរអោយអ្នកដឹកនាំក្រុមជំនុំនៅហ្គាបុងបានឃើញព័ន្ធកិច្ចស្ត្រីនៃក្តីសង្ឃឹមនៃTWRមិនមែនគ្រាន់តែជាការប្រកួតប្រជែងនោះទេ ប៉ុន្តែជាអ្នកបំរើដែលឈរជាមួយគ្នា
ដើម្បីទៅឈោងចាប់ដល់មនុស្សកាន់តែច្រើនសម្រាប់អាណាចក្ររបស់ទ្រង់។ (សាស្តា៤:៩)

7. ព្រះវរបិតាអើយ
សូមនាំមកនូវការសង្គ្រោះដល់ប្រជាជនក្រីក្រដែលត្រូវគេជិះជាន់នៅលីបេរីយ៉ា និងផ្តល់គ្រប់តម្រូវការរបស់ពួកគេដែលត្រូវការផងដែរ។
សូមផ្តល់ប្រាជ្ញាដល់អ្នកដឹកនាំក្នុងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេកុំអោយកាន់តែមានការយ៉ាប់យ៉ឺននោះឡើយ។ (ទំនុកដំកើង៩:៩)

8. បិតាអើយ សូមពង្រឹងក្តីជំនឿ និងកម្លាំងបេសកជននៅប្រទេសកាមេរូន សូមផ្គត់ផ្គង់តម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ នៅពេលដែលពួកគេបម្រើទ្រង់។ (២កូរិនថូស៩:៨)

9. មានទំនៀមទំលាប់មួយចំនួននៅទ្វីបអាហ្វ្រិក
លើកទឹកចិត្តឲ្យមានអំពើផិតក្បត់នៅក្នុងគ្រួសារ។ ឱព្រះបិតាអើយ
សូមធ្វើការនៅក្នុងចិត្តនៃអ្នកដែលអាចនាំមកនូវការផ្លាស់ប្តូរ
ហើយកំសាន្តចិត្ត និងការពារកុមារដែលម្តាយគេបានបោះបង់ចោលដោយសារអំពើបាបទាំងនេះផងដែរ។ (លោកុប្បត្តិ១០:១៤)

**Phum Roung Chak, Sangkat Kok Kleang,**

**Khan Sen Sok, Phnom Penh**

**ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខ័ណ្ឌសែនសុខរាជធានីភ្នំពេញ )**

**Tel: 092 60 60 51 /086 60 60 56**

10. ព្រះអម្ចាស់អើយ យើងសូមថ្វាយការរៀបចំកម្មវិធី Catch Them Young ក្នុងព្រហស្ដរបស់ទ្រង់
និងអធិស្ឋានថាកុមារដែលមានអាយុអាចចូលរៀនជាច្រើននៅក្នុងប្រទេសនីហ្សេរីយ៉ានោះនឹងមានការណែនាំអោយស្គាល់ព្រះនាមព្រះយេស៊ូវ។ (សុភាសិត២២:៦)

11. ព្រះអើយ សូមបន្តផ្គត់ផ្គង់នូវវិទ្យុដល់អ្នកស្តាប់នៅម៉ាលី
សូមអោយក្រុមអ្នកស្តាប់ដែលបានបង្កើតឡើងនៅ Boardie និងDiola ក្លាយជាក្រុមដែលមានជំនឿរឹងមាំ។ (១ថែស្សាឡូនីច៥:១១)

12. ព្រះអម្ចាស់អើយ
យើងខ្ញុំសូមអធិស្ឋានសម្រាប់ឱកាសក្នុងការទទួលបានការអប់រំដល់ស្ត្រីនៅ Côte d'Ivoire ដើម្បីអោយពួកគេអាចក្លាយជាអ្នកចេះអក្សរ
និងបានរៀនថ្នាក់កុំព្យូទ័រដែលជំនាញ។ (សុភាសិត១៨:១៥)

13. ឱព្រះវរបិតាអើយ
ទូលបង្គំទូលសូមអោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់នឹងនាំការក្រោកឈរឡើងវិញដល់ព្រះវិហារនៅហ្គាបុង និង
សូមអោយក្រុមជំនុំនៅទីនោះបានក្លាយជាអំបិលនៃផែនដី និងពន្លឺនៃពិភពលោកផងដែរ។ (ម៉ាថាយ៥:១៣-១៤)

14. ព្រះអម្ចាស់អើយ
សូមជួយកុមារគ្រីស្ទបរិស័ទនៅប្រទេសលីបេរីយ៉ាឱ្យក្លាយជាក្មេងដែលស្តាប់បង្គាប់មាតាបិតារបស់ពួកគេ ដើម្បីឲ្យពួកគេទទួលបានពរជ័យ និងមានអាយុវែង។ (និក្ខមនំ២០:១២)

15. ឱព្រះវរបិតាអើយ
ទូលបង្គំសូមអធិស្ឋានអោយមានការផ្លាស់ប្តូរចិត្តគំនិតរបស់មនុស្សដែលគ្មានទំនួលខុសត្រូវ ដើម្បីអោយពួកគេមានការថែទាំក្រុមគ្រួសាររបស់ពួកគេអោយបានត្រឹមត្រូវ។ (១ធីម៉ូថេ៥:៨)

16. យើងខ្ញុំសូមអរព្រះគុណព្រះអង្គសម្រាប់ Victa Media Communicationsក្នុងការធ្វើជាដៃគូជាមួយយើងនៅក្នុងប្រទេសនីហ្សេរីយ៉ា។ សូមប្រើព័ន្ធកិច្ចដ៏អស្ចារ្យនេះទៅតាមបំណងរបស់ទ្រង់។ (យេរេមា៥១:២០-២៤)

17.
នៅប្រទេសម៉ាលីមានរបាយការណ៍ជាច្រើនអំពីស្ត្រីត្រូវបានសម្លាប់ដោយស្វាមីរបស់ពួកគេដោយមិនដឹងពីមូលហេតុ។ ឱព្រះវរបិតាអើយ
សូមទ្រង់ការពារស្ត្រីទាំងនោះនៅក្នុងស្ថានភាពដ៏អស់សង្ឃឹមមួយនេះ។ (សុភាសិត៣១:៨-៩)

18.
យើងសូមសរសើរព្រះនាមទ្រង់សម្រាប់ការបើកឡើងវិញនៃកន្លែងថ្វាយបង្គំនៅ Côte d'Ivoire។ សូមទ្រង់ដឹកនាំក្រុមការងារស្ត្រីក្នុងសង្ឃឹមក្នុងការដែលពួកគេចាប់ផ្តើមឡើងវិញនៅព័ន្ធកិច្ចដែលត្រូវជួបជាមួយក្រុមអ្នកស្តាប់ផ្ទាល់។ (ហេព្រើរ១០:២៤-២៥)

19. ព្រះវរបិតាដ៏មានព្រះហឫទ័យមេត្តាករុណាអើយ
ទូលបង្គំសូមអធិស្ឋានឲ្យទ្រង់ផ្គត់ផ្គង់នូវគ្រប់ទាំងសេចក្តីត្រូវការដែលស្ត្រីនៅក្នុងប្រទេសហ្គាបុងត្រូវការ ភាគច្រើនពួកគេជាស្ត្រីដ៏ក្រីក្រខ្លាំងណាស់។ សូមឆ្លើយតបការអធិស្ឋានរបស់អស់អ្នកដែលចង់រៀបការ និង មានគ្រួសារ។ (ទំនុកតម្កើង៨២:៣)

20. មានយុវជនជាច្រើននៅក្នុងប្រទេសលីបេរីយ៉ា
មានការពាក់ព័ន្ធជាមួយនឹងគ្រឿងញៀន ការលួច និង ការរំលោភ។
ឱព្រះវបិតាអើយ សូមឲ្យប្រវាក់ទាំងនេះត្រូវបានបំបែក ហើយជួយយុវជនទាំងនោះអោយទទួលបានសេរីភាពនៅក្នុងទ្រង់ផងដែរ។ (សាស្តា១២:១)